ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីព្រាង

# ច្បាប់
# ស្តីពី
# ការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.**

ច្បាប់នេះមានគោលបំណងការពារសុខភាពសាធារណៈបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់ទៅលើសេដ្ឋកិច្ច និងសង្គម។

**មាត្រា ២.**

ច្បាប់នេះមានគោលដៅដូចតទៅ:

- ចាត់វិធានការក្នុងការគ្រប់គ្រង និងត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង
- លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជនអំពីគ្រោះថ្នាក់នៃការប្រើប្រាស់ផលិតផលគ្រឿងស្រវឹង
- សហការជាមួយបណ្ដាក្រសួង ស្ថាប័នជាតិ អន្តរជាតិ និងអង្គការដៃគូនានា ដើម្បីជំរុញការអប់រំ និងកាត់បន្ថយការប្រើប្រាស់ផលិតផលគ្រឿងស្រវឹង។

**មាត្រា ៣.**

ច្បាប់នេះមានវិសាលភាព ត្រួតពិនិត្យការប្រើប្រាស់ផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទដែលផលិត នៅក្នុងស្រុក ឬនាំចូលពីបរទេស ហើយចែកចាយលក់ និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.**

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មានខ្លឹមសារជាអាទិ៍៖

- **ផលិតផលគ្រឿងស្រវឹង** សំដៅដល់ផលិតផលគ្រប់ប្រភេទដែលផ្សំឡើងពីអេតាណុលលើសពី ១% នៃបរិមាណរបស់ទឹក ឬគួបផ្សំជាមួយសារជាតុដទៃទៀត ដែលបង្កើតឡើងដោយឧស្សាហករគ្រឿងស្រវឹង និងដោយមធ្យោបាយផ្សេងៗ ទៀត ប្រើប្រាស់សម្រាប់ផឹកដោយផ្ទាល់ ឬដោយទម្រង់ផ្សេងៗទៀត។
- **ឧស្សាហករគ្រឿងស្រវឹង** សំដៅដល់អ្នកផលិតគ្រឿងស្រវឹង អ្នកលក់ដុំ និងអ្នកនាំចូលពីបរទេសនូវផលិតផលគ្រឿងស្រវឹង។

- **ការផ្សាយពាណិជ្ជកម្ម និងការលើកកម្ពស់ការលក់ផលិតផលគ្រឿងស្រវឹង** សំដៅដល់ការផ្សព្វផ្សាយតាមគ្រប់មធ្យោបាយទាំងអស់។
- **ការឧបត្ថម្ភកម្មវិធីដោយឧស្សាហកម្មគ្រឿងស្រវឹង** សំដៅដល់រាល់ទម្រង់នៃវិភាគទានចំពោះព្រឹត្តិការណ៍ សកម្មភាព ឬបុគ្គលណាមួយ ដោយមានគោលបំណង មានអានុភាពលើ ឬអាចមានអានុភាពលើការផ្សព្វផ្សាយផលិតផលគ្រឿងស្រវឹង ឬការប្រើប្រាស់ផលិតផលគ្រឿង ស្រវឹងដោយផ្ទាល់ ឬដោយប្រយោល។
- **ការលក់រាយ** សំដៅដល់ការលក់នៅនឹងទីកន្លែង និងចល័ត។
- **គ្រឹះស្ថានសិក្សា** សំដៅដល់មជ្ឈមណ្ឌលអប់រំសិក្សាបណ្តុះបណ្តាលដោយគិតចាប់ពីកម្រិតមត្តេយសិក្សាដល់ឧត្តមសិក្សា ទោះជាប្រភេទសាលារៀន ឬវិទ្យាស្ថាន ឬសាកលវិទ្យាល័យ ឬមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈគ្រប់កម្រិត។
- **គ្រឹះស្ថានសុខាភិបាល** សំដៅដល់ប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យ គ្លីនិកសុខភាព ឱសថស្ថាន មន្ទីរពិសោធន៍សុខាភិបាល ជាដើម។
- **ទីកន្លែងសាធារណៈ** សំដៅដល់ទីកន្លែង ទីតាំងអគារ និងមធ្យោបាយដឹកជញ្ជូននានា ដែលជាកម្មសិទ្ធិរដ្ឋ សាធារណៈ ឬឯកជនដែលបើកទូលាយ និងផ្តល់សេវាដល់សាធារណជនទូទៅ។
- **គ្រឹះស្ថានសាសនា** សំដៅដល់ព្រះវិហារ ធម្មសភា សាលាបុណ្យ កុដិ បណ្ណាល័យ សាលាពុទ្ធិកសិក្សា អាស្រម មណ្ឌលវិបស្សនា វិហារស៊ូរ៉ាវ ជាដើម ដែលទីកន្លែងទាំងនោះ ប្រើប្រាស់ក្នុងគោលបំណងគោរពបូជាសាសនាផ្សេងៗ ក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២
## សមត្ថកិច្ចត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង

**មាត្រា ៥..**

ក្រសួងសុខាភិបាលជាស្ថាប័នបង្គោលជាតិ មានសមត្ថកិច្ចក្នុងការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ។៚

ក្រសួងសុខាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការ និង/ឬ ធ្វើប្រតិបត្តិការត្រួតពិនិត្យ រាល់សកម្មភាពដែលពាក់ព័ន្ធទៅនឹងការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទដែលបញ្ញត្តិក្នុងច្បាប់នេះ។

**មាត្រា ៦.-**

ក្រសួងសុខាភិបាលជាស្ថាប័នទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាជាមួយបណ្តាប្រទេសនានា អង្គការជាតិ និងអង្គការអន្តរជាតិ មានសមត្ថកិច្ចក្នុងការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ។

ក្នុងតួនាទីជាស្ថាប័នមានសមត្ថកិច្ចរបស់ជាតិ ក្រសួងសុខាភិបាលត្រូវទទួលខុសត្រូវក្នុងការបំពេញមុខងាររដ្ឋបាលធ្វើជាស្ថាប័នទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអង្គការជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធ។

**មាត្រា ៧.-**

រាជរដ្ឋាភិបាល ត្រូវបង្កើតគណៈកម្មាធិការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ផលិតផលគ្រឿងស្រវឹង។

គណៈកម្មាធិការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង ត្រូវដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ។

គណៈកម្មាធិការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹងត្រូវបង្កើតដោយអនុក្រឹត្យ។

រាជរដ្ឋាភិបាល បង្កើតយន្តការមួយចំនួនតាមការចាំបាច់ តាមសំណើរបស់ក្រសួងសុខាភិបាល ហើយយន្តការទាំងនេះត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី ៣
## ការបង្ហាញព័ត៌មានសារធាតុពុល និងញៀន
## ក្នុងផលិតផលគ្រឿងស្រវឹង

**មាត្រា ៨.-**

ផលិតករក្នុងស្រុក និងអ្នកនាំចូលពីបរទេស សម្រាប់ធ្វើការចែកចាយ និងលក់ផលិតផលគ្រឿងស្រវឹង គ្រប់ប្រភេទ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តល់ជូនក្រសួងសុខាភិបាលនូវព័ត៌មាន លម្អិតស្តីអំពី កំហាប់ជាតិអេតាណុល សារជាតុពុល និងញៀន និងសារជាតុផ្សេងៗ ដែលមានក្នុងផលិតផលគ្រឿងស្រវឹងដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។/.

**មាត្រា ៩.-**

ផលិតករក្នុងស្រុក និងអ្នកនាំចូលពីបរទេស សម្រាប់ធ្វើការចែកចាយ និងលក់ផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើការបោះពុម្ពឬបិតស្លាកសញ្ញាស្តីអំពីព័ត៌មានលម្អិតនៃកំហាប់ជាតិអេតាណុល សារជាតុពុល និងសារជាតុផ្សេងៗ ដែលមានក្នុងផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទ និងសារព្រមានសុខភាពនៅលើកំប៉ុង ប្រអប់ ឬដប ជាដើម។

ស្លាកសញ្ញាស្តីអំពីព័ត៌មានលម្អិតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

ស្លាកសញ្ញាសារព្រមានសុខភាពស្តីពីផលប៉ះពាល់ដែលពាក់ព័ន្ធនឹងផលិតផលគ្រឿងស្រវឹងត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី ៤
## វិធានការចំពោះការផ្សាយពាណិជ្ជកម្ម ការលើកកម្ពស់ផ្សព្វផ្សាយ លក់ និងការឧបត្ថម្ភកម្មវិធីដោយឧស្សាហករគ្រឿងស្រវឹង

**មាត្រា ១០.-**

វិធានការហាមឃាត់ និងការទប់ស្កាត់រាល់ការផ្សាយពាណិជ្ជកម្ម ការលើកកម្ពស់ និងការឧបត្ថម្ភកម្មវិធីដោយឧស្សាហករគ្រឿងស្រវឹង ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី ៥
## ការចែកចាយ ការលក់ ការប្រើប្រាស់ និងទីកន្លែងលក់ផលិតផលគ្រឿងស្រវឹង

**មាត្រា ១១.-**

ការផលិត ការនាំចូល ការចែកចាយ ការលក់ដុំ និងការលក់រាយផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទ ត្រូវតែមានការអនុញ្ញាតពីក្រសួងមានសមត្ថកិច្ចដែលត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ១២.-**

ហាមលក់ ឬចែកចាយ ផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទដល់៖

- ជនដែលមានអាយុក្រោម ២១ (ម្ភៃមួយ) ឆ្នាំ៖

- ស្ត្រីមានគភ៌ កាលបើគត់ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើខ្លួនបានដឹង
- ជនស្ថិតក្នុងស្ថានភាពស្រវឹងដែលមិនអាចគ្រប់គ្រងខ្លួនឯងបាន។

**មាត្រា ១៣.-**

- ហាមលក់ផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទចាប់ពីម៉ោង ១២:០០ យប់ រហូត ដល់ម៉ោង ០៦:០០ ព្រឹក លើកលែងតែទីតាំងមួយចំនួនដែលកំណត់ដោយអនុក្រឹត្យ។
- ហាមលក់ផលិតផលគ្រឿងស្រវឹងតាមរយៈម៉ាស៊ីនស្វ័យប្រវត្តិ។

**មាត្រា ១៤.-**

ការលក់ ចែកចាយ ឬប្រើប្រាស់ផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទនៅក្នុងបរិវេណ នៃទីតាំងដូចខាងក្រោមត្រូវហាមឃាត់៖

- គ្រឹះស្ថានសុខាភិបាលគ្រប់ប្រភេទ
- គ្រឹះស្ថានសិក្សាគ្រប់ប្រភេទ
- ក្លឹបកីឡា
- គ្រឹះស្ថានសាសនា
- សួនច្បារសាធារណៈ
- ការិយាល័យធ្វើការរដ្ឋ
- អន្តេវាសិកដ្ឋាន សម្រាប់ឱ្យនិស្សិតស្នាក់នៅ។

កន្លែងផ្សេងទៀតដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា ១៥.-**

រាល់ការនាំយកមកជាមួយខ្លួននូវផលិតផលគ្រឿងស្រវឹងដើម្បីប្រើប្រាស់ផ្ទាល់ខ្លួនចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា លើសពី ២ (ពីរ) លីត្រ ត្រូវហាមឃាត់។

ជនដែលមានអាយុតិចជាង ២១ (ម្ភៃមួយ)ឆ្នាំ មិនអនុញ្ញាតឲ្យនាំយកមកជាមួយខ្លួននូវផលិតផលគ្រឿងស្រវឹងចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ។៤

# ជំពូកទី ៦
# ការផ្តល់ព័ត៌មាន ការលើកកម្ពស់ការយល់ដឹង និងការចូលរួម របស់សាធារណជន

## មាត្រា ១៦.-

ក្រសួងសុខាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវលើកកម្ពស់ការយល់ដឹងធ្វើការអប់រំ និង ផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់សាធារណជន អំពីផលប៉ះពាល់លើសុខភាព សេដ្ឋកិច្ច និងបរិស្ថានដែល បណ្តាលមកពីការប្រើប្រាស់ផលិតផលគ្រឿងស្រវឹង។

ក្រសួងសុខាភិបាល ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល និងផ្នែកឯកជន ដើម្បីជំរុញកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីផលវិបាកនៃការប្រើប្រាស់ផលិតផលគ្រឿងស្រវឹង។

ក្រសួងសុខាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងសាធារណៈ និងឯកជន ត្រូវលើកទឹកចិត្ត ដល់ការចូលរួមរបស់សាធារណជនក្នុងកម្មវិធីលើកកម្ពស់ការយល់ដឹងជាសាធារណៈតាមរយៈការអប់រំ និងយុទ្ធនាការផ្សព្វផ្សាយទូលំទូលាយទូទាំងប្រទេស និងជួយអ្នកប្រើប្រាស់ផលិតផលគ្រឿងស្រវឹងឱ្យឈប់ប្រើប្រាស់ផលិតផលគ្រឿងស្រវឹង និងត្រូវផ្តល់សេវាពិគ្រោះយោបល់ និងព្យាបាលដល់អ្នកដែលទទួលផលប៉ះពាល់ពាល់ផលិតផលគ្រឿងស្រវឹង។

## មាត្រា ១៧.-

ក្រសួងទទួលបន្ទុកវិស័យអប់រំត្រូវបញ្ជ្រាបចូលក្នុងកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីផលវិបាកនៃការប្រើប្រាស់គ្រឿងស្រវឹងទៅក្នុងកម្មវិធិសិក្សាចំណេះទូទៅនៅគ្រប់កម្រិតសិក្សា និងក្នុងកម្មវិធីឧត្តមសិក្សាទាំងរបស់គ្រឹះស្ថានសាធារណៈ និងឯកជន ទាំងគ្រឹះស្ថានសិក្សាដែលផ្តល់ការសិក្សាជំនាញបច្ចេកទេស និងវិជ្ជាជីវៈ។

## មាត្រា ១៨.-

ក្រសួងព័ត៌មានត្រូវផ្តល់ជូន និងសម្របសម្រួលការផ្សព្វផ្សាយនូវកម្មវិធីអប់រំសុខភាព និងលើកកម្ពស់ការយល់ដឹងអំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងស្រវឹងឱ្យបានទូលំទូលាយ។៚

## ជំពូកទី ៧
## គោលនយោបាយពន្ធ និងប្រភពធនធាន

**មាត្រា ១៩.-**

រាជរដ្ឋាភិបាល ត្រូវមានគោលនយោបាយតម្លើងពន្ធលើផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទ។

**មាត្រា ២០.-**

រាជរដ្ឋាភិបាលត្រូវឲ្យមានមូលនិធិត្រួតពិនិត្យផលិតផលគ្រឿងស្រវឹងដើម្បីអប់រំ និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ដឹងអំពីផលប៉ះពាល់នៃការប្រើប្រាស់ផលិតផលគ្រឿងស្រវឹង និងស្រាវជ្រាវ វាយតម្លៃកម្មវិធីត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង។

មូលនិធិត្រួតពិនិត្យផលិតផលគ្រឿងស្រវឹងនេះត្រូវបង្កើតឡើងដោយអនុក្រឹត្យ។

**មាត្រា ២១.-**

ប្រភពធនធានសម្រាប់អនុវត្តច្បាប់នេះ និងដំណើរការនៃយន្តការនានា នឹងបានមកពី៖

- ថវិកាជាតិ និងធនធានដទៃទៀតពីរាជរដ្ឋាភិបាល
- អំណោយនានាពីសប្បុរសជនជាតិ និងអន្តរជាតិ
- អំណោយឧបត្ថម្ភពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ
- ប្រាក់ចំណូលនានាពីប្រតិបត្តិការនៃច្បាប់នេះ។
- ប្រាក់ពិន័យអន្តរការណ៍។

## ជំពូកទី ៨
## អធិការកិច្ចផលិតផលគ្រឿងស្រវឹង

**មាត្រា ២២.-**

ក្រសួងសុខាភិបាល ត្រូវចាត់តាំងមន្ត្រីជំនាញរបស់ក្រសួងជាមន្ត្រីអធិការកិច្ចផលិតផលគ្រឿងស្រវឹង ដើម្បីតាមដាន ត្រួតពិនិត្យ និងជម្រុញការអនុវត្តច្បាប់នេះ។

## មាត្រា ២៣.-

ក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការទាក់ទងនឹងការធ្វើអធិការកិច្ច ដែលមានចែងក្នុងច្បាប់នេះ មន្ត្រីអធិការកិច្ចផលិតផលគ្រឿងស្រវឹងមានសិទ្ធិធ្វើការត្រួតពិនិត្យ និងចាត់វិធានការដូចខាងក្រោមៈ

- ធ្វើការត្រួតពិនិត្យជាប្រចាំទៅលើការប្រើប្រាស់ ការលក់ និងការផ្សព្វផ្សាយពាណិជ្ជកម្ម និងការបោះពុម្ពសារព្រមានសុខភាពលើផលិតផលគ្រឿងស្រវឹងរបស់ឧស្សាហករគ្រឿងស្រវឹង
- ស្នើសុំត្រួតពិនិត្យ និងធ្វើតេស្តលើសមាសធាតុផលិតផលគ្រឿងស្រវឹងដែលមាននៅក្នុងផលិតផលគ្រឿងស្រវឹង
- ចាត់វិធានការហាមឃាត់ជាបណ្តោះអាសន្នចំពោះការចែកចាយ ឬការចរាចរលើទីផ្សារនូវប្រភេទផលិតផលគ្រឿងស្រវឹងទាំងឡាយណា ដែលបានស្រាវជ្រាវឃើញនូវសមាសធាតុដែលបង្កហានិភ័យខ្ពស់ក្នុងផលិតផលគ្រឿងស្រវឹង ឬបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះសុខភាពមនុស្ស និងបរិស្ថាន
- ត្រួតពិនិត្យ និងពិន័យអន្តរការណ៍ចំពោះការមិនអនុវត្តបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធជាមួយនឹងការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង
- ចាប់យកវត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាងនៃបទល្មើស
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

នីតិវិធីនៃការធ្វើអធិការកិច្ចផលិតផលគ្រឿងស្រវឹង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

## មាត្រា ២៤.-

មន្ត្រីអធិការកិច្ចផលិតផលគ្រឿងស្រវឹងទទួលនីតិសម្បទាអោយពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចផលិតផលគ្រឿងស្រវឹងត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។៚

## មាត្រា ២៥..

រាល់ប្រតិបត្តិការពិនិត្យបទល្មើសរបស់មន្ត្រីអធិការកិច្ចផលិតផលគ្រឿងស្រវឹង ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ចផលិតផលគ្រឿងស្រវឹងមានសិទ្ធស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់ថ្នាក់ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើស ដែលមានចែងក្នុងច្បាប់នេះ ។

## មាត្រា ២៦..

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចផលិតផលគ្រឿងស្រវឹង ត្រូវស្លៀកពាក់ឯកសណ្ឋាន និងមានបណ្ណសម្គាល់ខ្លួន ព្រមទាំងមានលិខិតអនុញ្ញាតឲ្យបំពេញបេសកកម្ម។

ឯកសណ្ឋាន និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផលិតផលគ្រឿងស្រវឹង ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

## មាត្រា ២៧..

បុគ្គលដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចផលិតផលគ្រឿងស្រវឹង អាចធ្វើបណ្ដឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការទៅរដ្ឋមន្ត្រីក្រសួងសុខាភិបាល គិតចាប់ពីថ្ងៃទទួលបានសេចក្ដីសម្រេច ឬថ្ងៃដកហូត។

រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវសម្រេចបណ្ដឹងក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលពាក់បណ្ដឹង។

ក្នុងករណីដែលបុគ្គលណាមិនសុខចិត្ត ចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល បុគ្គលនោះមានសិទ្ធិធ្វើបណ្ដឹងទៅតុលាការតាមនីតិវិធី។

## មាត្រា ២៨..

នៅពេលប្រតិបត្តិការអនុវត្តច្បាប់នេះ ក្នុងករណីវត្ថុតាងនាំបទល្មើសជាផលិតផលហាមឃាត់ ឬមានគ្រោះថ្នាក់ មន្ត្រីអធិការកិច្ចផលិផលគ្រឿងស្រវឹងមានសិទ្ធស្នើសុំដីកាសម្រេចរបស់ព្រះរាជអាជ្ញា ដើម្បីការបំផ្លាញចោលដោយអនុលោមតាមនីតិវិធីជាធរមាន។

ការចំណាយលើការបំផ្លាញចោលវត្ថុតាងដូចមានចែងខាងលើ គឺជាបន្ទុករបស់ម្ចាស់វត្ថុតាងនៃបទល្មើស។៤

**មាត្រា ២៩.-**

ប្រាក់ពិន័យអន្តរការណ៍ ត្រូវបង់ចូលថវិកាជាតិ។

រាជរដ្ឋាភិបាលអាចសម្រេចផ្ដល់រង្វាន់លើកទឹកចិត្តដល់មន្ត្រី ដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសជាក់លាក់ណាមួយដែលចែងក្នុងច្បាប់នេះ។

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

**មាត្រា ៣០.-**

ផលិតករក្នុងស្រុក និងអ្នកនាំចូលពីបរទេសសំរាប់ធ្វើការចែកចាយ និងលក់ផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទ ដែលមិនអនុវត្តតាមបទប្បញ្ញតិដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះត្រូវផ្ដន្ទាទោស ដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវផ្ដន្ទាទោសទ្វេដង។

**មាត្រា ៣១.-**

ផលិតករក្នុងស្រុកនិងអ្នកនាំចូលពីបរទេសសម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់ផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀលទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្ដន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តិបទល្មើសដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្ដន្ទាទោសពិន័យទ្វេដង។

**មាត្រា ៣២.-**

អ្នកផលិត អ្នកនាំចូល អ្នកចែកចាយ និងអ្នកលក់ដុំផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល។

ក្នុងករណីធ្លាប់ទទួលរងការផ្ដន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តិបទល្មើសដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្ដន្ទាទោសពិន័យទ្វេដង។៚

**មាត្រា ៣៣.-**

អំពើលក់ ឬចែកចាយផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទ ដល់ជនដែលមានអាយុក្រោម ២១ (ម្ភៃមួយ) ឆ្នាំ ស្ត្រីមានគភ៌ កាលបើគភ៌នោះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើខ្លួនបានដឹង ឬជនស្ថិតនៅក្រោមស្ថានភាពស្រវឹងមិនអាចគ្រប់គ្រងខ្លួនឯងបាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង។

**មាត្រា ៣៤.-**

អំពើលក់ និងចែកចាយផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង។

**មាត្រា ៣៥.-**

អំពើលក់ ឬការចែកចាយផលិតផលគ្រឿងស្រវឹងគ្រប់ប្រភេទ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិ មាត្រា ១៤ នៃច្បាប់នេះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តិបទល្មើសដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង។

**មាត្រា ៣៦.-**

រាល់បរិមាណ ចំនួនផលិតផលគ្រឿងស្រវឹង ដែលត្រូវបានបញ្ញត្តហាមឃាត់ដោយមាត្រា ១៥ នៃច្បាប់នេះ ត្រូវរឹបអូសដោយមន្ត្រីមានសមត្ថកិច្ច។៚

**មាត្រា ៣៧.-**

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៣០ ដល់មាត្រា ៣២ និងមាត្រា ៣៤ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវពិន័យជាប្រាក់ទ្វេដងព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅ៖

១.ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

២.ការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមព្រហ្មទណ្ឌ។

៣.ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ។

៤.ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ។

៥.ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍) នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី ១០
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៨.-**

បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹងដែលនៅជាធរមាន នៅមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

# ជំពូកទី ១១
# អវសានប្បញ្ញត្តិ

**មាត្រា ៣៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ខែ ឆ្នាំ
ក្នុងសម័យប្រជុំរដ្ឋសភាលើកទី នីតិកាលទី
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

## មាតិកាពិស្ដារ ទំព័រ

ជំពូកទី១ បទប្បញ្ញត្តិទូទៅ ........ ១
មាត្រា ១........ ១
មាត្រា ២........ ១
មាត្រា ៣........ ១
មាត្រា ៤........ ១
ជំពូកទី ២ សមត្ថកិច្ចត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង ........ ២
មាត្រា ៥........ ២
មាត្រា ៦........ ៣
មាត្រា ៧........ ៣
ជំពូកទី ៣ ការបង្ហាញព័ត៌មានសារធាតុពុល និងញៀន
ក្នុងផលិតផលគ្រឿងស្រវឹង ........ ៣
មាត្រា ៨........ ៣
មាត្រា ៩........ ៤
ជំពូកទី ៤ វិធានការចំពោះការផ្សាយពាណិជ្ជកម្ម
ការលើកកម្ពស់ ផ្សព្វផ្សាយ លក់
និងការឧបត្ថម្ភកម្មវិធីដោយឧស្សាហករគ្រឿងស្រវឹង ........ ៤
មាត្រា ១០........ ៤
ជំពូកទី ៥ ការចែកចាយ ការលក់ ការប្រើប្រាស់
និងទីកន្លែងលក់ផលិតផលគ្រឿងស្រវឹង ........ ៤
មាត្រា ១១........ ៤
មាត្រា ១២........ ៤
មាត្រា ១៣........ ៥
មាត្រា ១៤........ ៥
មាត្រា ១៥........ ៥
ជំពូកទី ៦ ការផ្ដល់ព័ត៌មាន ការលើកកម្ពស់ការយល់ដឹង
និងការចូលរួមរបស់សាធារណជន ........ ៦

មាត្រា ១៦ ............................................................ ៦

មាត្រា ១៧ ............................................................ ៦

មាត្រា ១៨ ............................................................ ៦

ជំពូកទី ៧ គោលនយោបាយពន្ធ និងប្រភពធនធាន ............................ ៧

មាត្រា ១៩ ............................................................ ៧

មាត្រា ២០ ............................................................ ៧

មាត្រា ២១ ............................................................ ៧

ជំពូកទី ៨ អធិការកិច្ចផលិតផលគ្រឿងស្រវឹង ................................ ៧

មាត្រា ២២ ............................................................ ៧

មាត្រា ២៣ ............................................................ ៨

មាត្រា ២៤ ............................................................ ៨

មាត្រា ២៥ ............................................................ ៩

មាត្រា ២៦ ............................................................ ៩

មាត្រា ២៧ ............................................................ ៩

មាត្រា ២៨ ............................................................ ៩

មាត្រា ២៩ ............................................................ ១០

ជំពូកទី ៩ ទោសប្បញ្ញត្តិ .................................................. ១០

មាត្រា ៣០ ............................................................ ១០

មាត្រា ៣១ ............................................................ ១០

មាត្រា ៣២ ............................................................ ១០

មាត្រា ៣៣ ............................................................ ១១

មាត្រា ៣៤ ............................................................ ១១

មាត្រា ៣៥ ............................................................ ១១

មាត្រា ៣៦ ............................................................ ១១

មាត្រា ៣៧ ............................................................ ១២

ជំពូកទី ១០ អន្តរប្បញ្ញត្តិ ................................................. ១២

មាត្រា ៣៨ ............................................................ ១២

**ជំពូកទី ១១ អវសានប្បញ្ញត្តិ** .................................................... ១៣
**មាត្រា ៣៩**.................................................................................. ១៣៤